# ប្រាក់ឧបត្ថម្ភសម្រាប់ការសិក្សារបស់សិស្សវិទ្យាល័យ នៅខេត្តកាណាហ្គាវ៉ា
# សម្រាប់ឆ្នាំ2026
# (ការណែនាំលម្អិត៖វគ្គពេញម៉ោងក្រៅម៉ោងនិងការសិក្សាពីចម្ងាយ)

ក្រុមប្រឹក្សាអប់រំខេត្តកាណាហ្គាវ៉ា ការិយាល័យអប់រំ
នាយកដ្ឋានរដ្ឋបាល ផ្នែកហិរញ្ញវត្ថុ ក្រុមអាហារូបករណ៍វិទ្យាល័យ
(ខែសីហាឆ្នាំ 2026)

# 1 តើប្រាក់អាហារូបករណ៍ជាអ្វី?

○ នេះគឺជាប្រព័ន្ធផ្តល់ជំនួយដល់គ្រួសារដែលមានប្រាក់ចំណូលមធ្យម និងទាប ហើយមានកូនកំពុងសិក្សានៅវិទ្យាល័យ ឬគ្រឹះស្ថានអប់រំដែលមានលក្ខណៈសមមូល ដើម្បីឱ្យសិស្សទាំងអស់ដែលមានបំណងចង់សិក្សា អាចទទួលបានការអប់រំដោយគ្មានការព្រួយបារម្ភ។

○ នេះគឺជា**ប្រាក់ឧបត្ថម្ភ**សម្រាប់ជួយរ៉ាប់រងការចំណាយលើការអប់រំក្រៅពីថ្លៃសិក្សា(※)។

○**ប្រាក់ឧបត្ថម្ភនេះមិនតម្រូវឱ្យសងវិញទេ**។

※ការចំណាយលើការអប់រំក្រៅពីថ្លៃសិក្សា រួមមាន ថ្លៃសៀវភៅសិក្សា ថ្លៃសម្ភារៈសម្រាប់ការរៀន ថ្លៃសម្ភារៈប្រើប្រាស់ក្នុងសាលា ថ្លៃសម្ភារៈសម្រាប់ធ្វើដំណើរទៅសាលា ថ្លៃចំណាយលើសកម្មភាពក្រៅកម្មវិធីសិក្សា ថ្លៃសមាជិកភាពក្រុមប្រឹក្សាសិស្ស ថ្លៃសមាជិកភាពសមាគមមាតាបិតា និងគ្រូបង្រៀន (PTA) ថ្លៃសម្ភារៈសិក្សានៅពេលចូលរៀន ថ្លៃដំណើរទស្សនកិច្ចសិក្សា និងថ្លៃទំនាក់ទំនង ជាដើម។

# 2　អ្នកដែលមានសិទ្ធិទទួលបានប្រាក់អាហារូបករណ៍

○ដើម្បីមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភនេះ លោកអ្នកត្រូវតែបំពេញ**លក្ខខណ្ឌទាំងបី** ចាប់ពី ( 1 ) ដល់ ( 3 ) ខាងក្រោម៖

**( 1 ) គិតត្រឹមថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2026 អាណាព្យាបាលរបស់សិស្សត្រូវមានទីលំនៅក្នុងខេត្តកាណាហ្គាវ៉ា។**

**( 2 ) នៅថ្ងៃទី 1 ខែកក្កដាឆ្នាំ 2026 គ្រួសាររបស់លោកអ្នកត្រូវស្ថិតក្នុងប្រភេទណាមួយដូចខាងក្រោម៖**


- **គ្រួសារដែលកំពុងទទួលបានជំនួយសង្គម** (生活保護世帯) ដែលទទួលបានជំនួយសម្រាប់ការប្រកបរបរចិញ្ចឹមជីវិត (生業扶助)។
- **គ្រួសារដែលមិនជាប់ពន្ធប្រជាពលរដ្ឋក្នុងតំបន់** (住民税非課税世帯) ដែលចំនួនពន្ធលើប្រាក់ចំណូលក្នុងពន្ធប្រជាពលរដ្ឋ (住民税所得割) របស់អាណាព្យាបាលស្មើនឹង 0 យ៉ែន។
- **គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែល 2,700,000 ដល់ 3,800,000 យ៉ែន** ដែលចំនួនសរុបនៃពន្ធលើប្រាក់ចំណូលក្នុងពន្ធប្រជាពលរដ្ឋរបស់អាណាព្យាបាលមានចាប់ពី 100 យ៉ែនឡើងទៅ ប៉ុន្តែតិចជាង 105,500 យ៉ែន។
- **គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែល 3,800,000 ដល់ 4,900,000 យ៉ែន** ដែលចំនួនសរុបនៃពន្ធលើប្រាក់ចំណូលក្នុងពន្ធប្រជាពលរដ្ឋរបស់អាណាព្យាបាលមានចាប់ពី 105,500 យ៉ែនឡើងទៅ ប៉ុន្តែតិចជាង 182,500 យ៉ែន។

**( 3 ) គិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៦ សិស្សត្រូវកំពុងសិក្សានៅវិទ្យាល័យ ឬគ្រឹះស្ថានអប់រំដែលស្ថិតក្នុងប្រភេទកំណត់។**

- ពាក្យថា «សិស្សវិទ្យាល័យជាដើម» សំដៅលើសិស្សដែលមានសិទ្ធិទទួលបានប្រាក់ជំនួយថ្លៃសិក្សា (就学支援金) ប្រាក់ជំនួយការសិក្សាថ្មីសម្រាប់សិស្សវិទ្យាល័យជាដើម (高校生等・新修学支援金) ឬប្រាក់ជំនួយសម្រាប់ការចូលរៀនឡើងវិញ (学び直し支援金)។
- ពាក្យថា «វិទ្យាល័យ ឬគ្រឹះស្ថានអប់រំផ្សេងទៀត» សំដៅលើវិទ្យាល័យ (មិនរាប់បញ្ចូលវគ្គសិក្សាពិសេស 別科) សាលាមធ្យមសិក្សាប្រភេទរួមបញ្ចូលគ្នា (ថ្នាក់កម្រិតខ្ពស់) មហាវិទ្យាល័យបច្ចេកទេស (ចាប់ពីឆ្នាំទី 1 ដល់ឆ្នាំទី 3 ) ព្រមទាំងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រឹះស្ថានអប់រំប្រភេទផ្សេងៗដែលមានកម្មវិធីសិក្សាស្រដៀងនឹងកម្រិតវិទ្យាល័យ (មិនរាប់បញ្ចូលផ្នែកវិទ្យាល័យនៃសាលាអប់រំពិសេស)។

**(※ ក្រៅពីលក្ខខណ្ឌខាងលើ នៅមានលក្ខខណ្ឌផ្សេងទៀតទាក់ទងនឹងសញ្ជាតិ និងស្ថានភាពស្នាក់នៅក្នុងប្រទេសជប៉ុនជាដើម។)**

# 2 – 1　លក្ខខណ្ឌសម្រាប់ការទទួលបានប្រាក់អាហារូបករណ៍សម្រាប់ការសិក្សា



# 3 ចំនួនទឹកប្រាក់

| ប្រភេទគ្រួសារ | លក្ខខណ្ឌ | ពេញម៉ោង<br>ក្រៅម៉ោង | ពីចម្ងាយ |
|---|---|---|---|
| ①គ្រួសារដែលទទួលបានជំនួយសង្គម | កំពុងទទួលបានជំនួយសម្រាប់ការប្រកបរបរចិញ្ចឹមជីវិតគិតត្រឹមថ្ងៃទី១ ខែកក្កដា | 32, 300 យ៉ែន | |
| ②គ្រួសារដែលមិនជាប់ពន្ធប្រជាពលរដ្ឋក្នុងតំបន់ | ចំនួនសរុបនៃពន្ធដែលគិតតាមប្រាក់ចំណូលរបស់អាណាព្យាបាលទាំងអស់ស្មើនឹង ០ យ៉ែន<br>(មិនរាប់បញ្ចូលប្រភេទ ①) | 143, 700 យ៉ែន | 50, 500 យ៉ែន |
| ③គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែល 2, 700, 000–<br>3, 800, 000 យ៉ែន | ចំនួនសរុបនៃពន្ធដែលគិតតាមប្រាក់ចំណូលរបស់អាណាព្យាបាលទាំងអស់តិចជាង 105, 500 យ៉ែន (មិនរាប់បញ្ចូលប្រភេទ ① និង ②) | 47, 900 យ៉ែន | 16, 830 យ៉ែន |
| ④គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែល 3, 800, 000–<br>4, 900, 000 យ៉ែន | ចំនួនសរុបនៃពន្ធដែលគិតតាមប្រាក់ចំណូលរបស់អាណាព្យាបាលទាំងអស់តិចជាង 182, 500 យ៉ែន (មិនរាប់បញ្ចូលប្រភេទ ① ដល់ ③) | 35, 930 យ៉ែន | 12, 630 យ៉ែន |

- ក្នុងករណីដែលមិនជាប់ពន្ធដោយសារមិនមានអាសយដ្ឋាននៅក្នុងប្រទេសជប៉ុនដូចជាករណីត្រូវបានបញ្ជូនទៅបំពេញការងារនៅក្រៅប្រទេសជាដើម នោះនឹងមិនមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការសិក្សាឡើយ។
- ក្នុងករណីដែលសិស្សវិទ្យាល័យ ឬសិស្សនៅគ្រឹះស្ថានអប់រំដែលមានលក្ខណៈសមមូល កំពុងស្នាក់នៅក្នុងមណ្ឌលសុខុមាលភាពកុមារ (លើកលែងមណ្ឌលគាំទ្រការរស់នៅរបស់ម្តាយ និងកូន) ឬកំពុងស្ថិតក្រោមការចិញ្ចឹមបីបាច់របស់ឪពុកម្តាយចិញ្ចឹម ហើយមានការផ្តល់ថវិកាសម្រាប់ការធ្វើដំណើរទស្សនកិច្ចសិក្សា ឬការចិញ្ចឹមបីបាច់ពិសេសតាមប្រព័ន្ធគាំពារសុខុមាលភាពកុមារ នោះនឹងមិនមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការសិក្សានេះឡើយ។

# 4　កាលបរិច្ឆេទផុតកំណត់នៃការដាក់ពាក្យស្នើសុំ និងវិធីសាស្ត្រដាក់ពាក្យស្នើសុំ

## <រយៈពេលដាក់ពាក្យ>

**ចាប់ពីថ្ងៃអង្គារទី ２５ ខែសីហាឆ្នាំ ２０２６ – ថ្ងៃអង្គារទី １５ ខែធ្នូឆ្នាំ ２０２６**

## <កន្លែងដាក់ពាក្យស្នើសុំ>

**ការិយាល័យរដ្ឋបាលនៃសាលារៀនដែលសិស្សកំពុងសិក្សា (ឬធ្លាប់បានសិក្សា) គិតត្រឹមថ្ងៃទី1 ខែកក្កដា ឆ្នាំ2026។**

- ទោះបីជាសិស្សបានឈប់រៀន ឬផ្ទេរទៅសាលាផ្សេង ចាប់ពីថ្ងៃទី២ ខែកក្កដា ក៏ដោយ សូមដាក់ពាក្យស្នើសុំនៅសាលាដែលសិស្សបានចុះឈ្មោះសិក្សា គិតត្រឹមថ្ងៃទី១ ខែកក្កដា។
- ដោយសារឯកសារដែលបានដាក់ស្នើត្រូវឆ្លងកាត់ការពិនិត្យ សូមដាក់ពាក្យ និងឯកសារពាក់ព័ន្ធឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

**※ សម្រាប់សិស្សដែលកំពុងសិក្សា (ឬធ្លាប់បានសិក្សា) នៅវិទ្យាល័យដែលគ្រប់គ្រងដោយខេត្តកាណាហ្គាវ៉ា ជាគោលការណ៍ ត្រូវដាក់ពាក្យស្នើសុំតាមប្រព័ន្ធដាក់ពាក្យអេឡិចត្រូនិក (e-kanagawa)។**

- ក្នុងករណីដែលមិនអាចដាក់ពាក្យតាមប្រព័ន្ធអេឡិចត្រូនិកបាន ឬមានការលំបាកយ៉ាងខ្លាំងក្នុងការដាក់ពាក្យតាមប្រព័ន្ធនេះ ក៏អាចដាក់ពាក្យតាមទម្រង់ក្រដាសបានផងដែរ។ ក្នុងករណីនេះ សូមទាក់ទងទៅកាន់អ្នកទទួលបន្ទុកនៅសាលារៀន។
- សេចក្តីណែនាំអំពីរបៀបដាក់ពាក្យតាមប្រព័ន្ធអេឡិចត្រូនិក មាននៅលើគេហទំព័ររបស់ផ្នែកហិរញ្ញវត្ថុនៃខេត្តកាណាហ្គាវ៉ា តាមតំណខាងក្រោម៖

(https://www.pref.kanagawa.jp/docs/en7/cnt/f531013/__)។

# 5 វិធីសាស្ត្រ និងពេលវេលានៃការទទួលប្រាក់អាហារូបករណ៍

**<របៀបទទួលប្រាក់>**

- **ប្រសិនបើលោកអ្នកមានចំណាយសាលាក្រៅពីថ្លៃសិក្សាមិនទាន់បង់ ប្រាក់ឧបត្ថម្ភនឹងត្រូវយកទៅបង់ចំនួនដែលមិនទាន់បង់។**
  - នាយកសាលាត្រូវបញ្ជាក់ថាតើមានចំណាយសាលាក្រៅពីថ្លៃសិក្សាដែលមិនទាន់បង់ឬទេ។
- ប្រាក់នឹងត្រូវផ្ទេរចូលគណនីធនាគារដែលបានសរសេរក្នុងទម្រង់ពាក្យស្នើសុំ។

**<ពេលទទួលប្រាក់>**

- គ្រោងនៅ **ប្រហែលចុងខែ ក្រោយ ២–៣ ខែ** ពីខែដែលលោកអ្នកដាក់ពាក្យ
  - ប្រសិនបើមានមនុស្សច្រើនដាក់ពាក្យក្នុងពេលតែមួយការបង់ប្រាក់អាចយឺត។

# 6 ឯកសារចាំបាច់សម្រាប់ការដាក់ពាក្យស្នើសុំ


សូមដាក់ជូនឯកសារចាំបាច់ទៅតាមប្រភេទនៃការដាក់ពាក្យស្នើសុំនីមួយៗ។

| ប្រភេទពាក្យ | ពាក្យស្នើសុំ | លិខិតបញ្ជាក់ជំនួយសង្គម | លិខិតបញ្ជាក់ពន្ធជាដើម | ឯកសារសញ្ជាតិជាដើម | ច្បាប់ចម្លងសៀវភៅធនាគារជាដើម | លិខិតប្រគល់សិទ្ធិ |
|---|---|---|---|---|---|---|
| គ្រួសារទទួលជំនួយសង្គម 生活保護世帯 | ● | ● | - | ● | ● | ▲（※） |
| បង់ពន្ធ / លើកលែងពន្ធ 課税・非課税世帯 | ● | - | ● | ● | ● | ▲（※） |
| ព័ត៌មានលម្អិត | មុខ៖P9 ក្រោយ៖P10 | P11 | P12 | P13 | P14 | P15 |

※លិខិតប្រគល់សិទ្ធិ តម្រូវឱ្យដាក់ជូនតែក្នុងករណីដែលសិស្សកំពុងសិក្សានៅ**<u>វិទ្យាល័យជាតិ ឬវិទ្យាល័យសាធារណៈ</u>** <u>ដែលមិនមែនជា**សាលាគ្រប់គ្រងដោយខេត្តកាណាហ្គាវ៉ា**</u> ហើយមានប្រាក់ចំណាយលើការអប់រំក្រៅពីថ្លៃសិក្សា **<u>ដែលនៅមិនទាន់បានបង់</u>**ប៉ុណ្ណោះ។

○ជាគោលការណ៍ ការដាក់ពាក្យស្នើសុំសម្រាប់សិស្សនៅវិទ្យាល័យដែលគ្រប់គ្រងដោយខេត្តកាណាហ្គាវ៉ា ត្រូវធ្វើឡើងតាមប្រព័ន្ធដាក់ពាក្យស្នើសុំអេឡិចត្រូនិក（e-kanagawa）។
សូមភ្ជាប់ឯកសារបន្ថែមទាំងអស់ ក្រៅពីទម្រង់ពាក្យស្នើសុំ ជាទិន្នន័យរូបភាពនៅក្នុងប្រព័ន្ធដាក់ពាក្យស្នើសុំអេឡិចត្រូនិក ហើយដាក់បញ្ជូនពាក្យស្នើសុំតាមប្រព័ន្ធនោះ។

# 6 – 1 – 1　ទម្រង់ពាក្យស្នើសុំ (ខាងមុខ) (គ្រប់គ្នាត្រូវដាក់)



第１号様式　　高校生等奨学給付金受給申請書　　年　月　日

殿

次のとおり、高校生等奨学給付金の受給を申請します。

【１】申請者について

| | | | |
|---|---|---|---|
| 保護者１ | フリガナ / 氏名 | 高校生等との関係 | □親権者（父）□親権者（母）□未成年後見人 □未成年後見人である里親 □主たる生計維持者 □生徒本人 □その他（　） |
| | 住所　〒 神奈川県 | 日中連絡が取れる電話番号 | |
| 保護者２ | フリガナ / 氏名 | 高校生等との関係 | □親権者（父）□親権者（母）□未成年後見人 □未成年後見人である里親 □主たる生計維持者 □生徒本人 □その他（　） |

【２】申請区分

| | |
|---|---|
| 通常給付 | □①生活保護受給世帯（生業扶助の高等学校等就学費を７月１日時点で受給している） |
| | □②住民税非課税世帯 |
| | □③令和８年度県民税・市民税所得割額合計100円～105,499円の世帯 |
| | □④令和８年度県民税・市民税所得割額合計105,500円～182,499円の世帯 |
| 家計急変 | □家計急変により保護者等の収入が減少した世帯 |

生活保護受給世帯であるにもかかわらず、②の世帯区分で申請した場合、奨学給付金を返還していただきます。

【３】高校生等の状況

| | | | |
|---|---|---|---|
| フリガナ / 氏名 | | 生年月日 | □平成 □西暦　年　月　日 |
| 在学する学校 | 学校の名称 | 立 | 課程 □全日制 □定時制 □通信制　在学年　年 |
| | 在学期間 | 自　年　月　日　～至　年　月　日 | |

| 過去の高等学校等における在学期間 | 学校名 | 在学期間 | 課程 | 在学中に給付金を受給した回数 |
|---|---|---|---|---|
| | | ～ | | □なし □１回 □２回 □３回 □４回 □不明 |
| | 学校名 | 在学期間 | 課程 | 在学中に給付金を受給した回数 |
| | | ～ | | □なし □１回 □２回 □３回 □４回 □不明 |

【４】国籍・在留資格

- □① 日本国籍
- □② 特別永住者
- □③ 永住者
- □④ 日本人の配偶者等
- □⑤ 永住者の配偶者等
- □⑥ 定住者のうち将来永住する意思がある
- □⑦ 家族滞在のうち、日本国の小学校、中学校を卒業した者であって、高校等卒業後に日本で就労して定着する意思がある
- □⑧ 上記以外（令和８年度新入生で在留資格「留学」除く）

（④～⑧の方のみ記入）在留期間満了日　年　月　日

⑥、⑦において意思がない場合は、⑧になります。⑧に該当する場合で、令和８年度新入生で在留資格が「留学」の場合は、本給付金は対象外となります。

【５】振込先口座

| | | | | | | |
|---|---|---|---|---|---|---|
| 振込先口座 | 金融機関名 | 銀行・信用金庫 信用組合・農協 | 金融機関コード | 支店名等 | 本店・支店・本所・支所・出張所 | 支店コード |
| | 預金種目 | 普通・当座・貯蓄 | 口座番号 | | 口座名義人（申請者） | |

【県使用欄】

| 保護者１所得割額 | 保護者２所得割額 | 所得割合算額（★） |
|---|---|---|
| | | |
| 支給決定額 | 学校充当額 | 申請者入金額 |
| | | |

| | | | | |
|---|---|---|---|---|
| 全日・定時 | ★=0円⇒143,700円 | 通信 | ★=0円⇒50,500円 | 生活保護 |
| | 0＜★＜105,500円⇒47,900円 | | 0＜★＜105,500円⇒16,830円 | 32,300円 |
| | 105,500円≦★＜182,500円⇒35,930円 | | 105,500円≦★＜182,500円⇒12,630円 | |

## 【１】 អំពីអ្នកដាក់ពាក្យ

- សូមសរសេរឈ្មោះ អាសយដ្ឋានរបស់ឪពុកម្តាយឬអាណាព្យាបាលនិងទំនាក់ទំនងដាមួយសិស្ស។

## 【２】 ប្រភេទពាក្យ

- សូមគូស (☑) ប្រភេទគ្រួសាររបស់លោកអ្នក។

## 【３】 អំពីសិស្ស

- សូមសរសេរឈ្មោះ ថ្ងៃខែឆ្នាំកំណើត សាលាជាដើមរបស់សិស្ស។

## 【４】 សញ្ជាតិ / ស្ថានភាពស្នាក់នៅ

- សូមគូស (☑) សញ្ជាតិឬស្ថានភាពស្នាក់នៅរបស់សិស្ស។
- ប្រសិនបើត្រូវនឹង ④–⑧ សូមសរសេរ «ថ្ងៃផុតកំណត់ស្នាក់នៅ» នៅខាងស្តាំផង។

## 【５】 គណនីធនាគារសម្រាប់ទទួលប្រាក់

- សូមសរសេរគណនីធនាគារសម្រាប់ទទួលប្រាក់អាហារូបករណ៍ (shogaku kyufukin)។

# 6 – 1 – 2　ទម្រង់ពាក្យស្នើសុំ (ខាងក្រោយ) (គ្រប់គ្នាត្រូវដាក់)



【6】申請書とともに提出する書類。
○生業扶助を受けていることがわかる書類もしくは課税状況がわかる書類について

| 所得状況 | 提出書類 | 備考 |
|---|---|---|
| □ 生活保護世帯 | 生活保護受給証明書 | 福祉事務所が７月１日以降に発行した生活保護受給証明書 |
| □ 生活保護世帯以外 | 次の者の（非）課税証明書等 | |
| | □ ①親権者（両親）２名 | 生徒が未成年（18歳未満）で、親権者が２人存在する場合<br>※単身赴任の場合も２名分必要 |
| | □ ②親権者１名 | 離婚、死別等により親権者が１名の場合<br>親権者は２名いるが、ＤＶや養育放棄、失踪等の事情によりやむを得ず、一方の親権者分を提出できない場合　等 |
| | □ ③未成年後見人 | 親権者が存在せず、未成年後見人が選任されている場合<br>※複数人選任されている場合は全員分 |
| | □ ④主たる生計維持者２名 | 生徒が在学中に成人した場合で、成人直前の未成年の時点から申請の時点まで生計を維持する者に変更がない場合 |
| | □ ⑤主たる生計維持者１名 | 生徒が未成年だが、親権者又は未成年後見人が存在しない場合<br>入学時点で生徒が成人であったが、主たる生計維持者が存在する場合<br>生徒が成人であり、未成年の時点で親権者が１人だった場合<br>生徒が成人であり、未成年の時点で親権者又は未成年後見人が存在しなかった場合　等 |
| | □ ⑥生徒本人 | 親権者、未成年後見人又は主たる生計維持者のいずれも存在しない場合であり、成人に達している場合　等 |

次の理由により、上表の書類を提出しません。
□ 所得確認の対象が生徒本人（親権者、未成年後見人又は主たる生計維持者のいずれも存在しない場合）であるが、未成年で道府県民税所得割・市町村民税所得割が課されるだけの収入を得ていないため

○国籍・在留資格等が確認できる書類について

| 国籍/在留資格 | 提出書類 | 備考 |
|---|---|---|
| □ 日本国籍 | 住民票の写し（原本） | |
| □ 特別永住者 | ・特別永住者証明書の写し<br>・住民票の写し（原本）　のいずれか | ・特別永住者証明書をコピーしたもの<br>・住民票の写しは国籍・在留資格等の記載があるもの |
| □ 永住者<br>□ 日本人の配偶者<br>□ 永住者の配偶者<br>□ 定住者<br>□ 留学（新入生除く） | ・在留カードの写し<br>・住民票の写し（原本）　のいずれか | ・在留カードはコピーしたもの<br>・住民票の写しは国籍・在留資格・在留期間等の記載があるもの<br>※永住者については、住民票の写しに在留期間の記載は不要です。<br>※定住者は、将来永住する意思がある者が対象です。 |
| □ 家族滞在 | ・在留カードの写し<br>・住民票の写し（原本）　のいずれか<br>及び、以下のいずれか一つ<br>日本の小学校及び中学校の<br>・卒業証書の写し<br>・卒業証明書の原本　のいずれか | ・在留カードはコピーしたもの<br>・住民票の写しは国籍・在留資格・在留期間等の記載があるもの<br>※小学校、中学校とは、特別支援学校（小・中）又は義務教育学校の前後期及び中等教育学校の前期課程も含みます。<br>※高校等卒業後、日本で就労して在留する意思がある者が対象です。 |

次の事項に同意する場合は、□にチェックを付けてください。
□ 高校生等就学支援金等の申請で提出した課税証明書や在留カードの写し等を使用して高校生等奨学給付金の支給審査をすることに同意します。

【7】誓約・委任

次のことを確認し、誓約（委任）します。　申請者氏名＿＿＿＿＿＿＿＿

・申請書の記載内容は事実に相違ありません。また、この申請書に虚偽の記載があった場合は、神奈川県教育委員会の求めに従いその全額を即時返還します。
・**神奈川県以外の都道府県に高校生等奨学給付金の申請は行っておりません。**
・この申請の対象となる高校生等は、７月１日時点※、児童福祉法による児童入所施設措置費等（見学旅行費又は特別育成費（母子生活支援施設の高校生等を除く。））の支弁対象ではありません。※家計急変申請は事由発生日の属する翌月の初日
・**（非課税世帯のみ）７月１日時点で生活保護（生業扶助（高等学校等就学費））を受けていません。**
・**（申請者が主たる生計維持者の場合のみ）**私と高校生等本人は、健康保険法等における扶養者と被扶養者の関係と同等の関係にあります。
・授業料以外に学校へ納付する納付金等に未済があるときは、私が支給を受ける高校生等奨学給付金をその未済に充てることについて学校長に委任します。
（注）神奈川県立学校以外の学校では、上記の下線部を次のように変更して使用。

【学校使用欄】
学校受付印

次のことについて確認しました。
・□　年７月１日現在、本校の（□全日制 □定時制 □通信制）課程に在学します。
・（□就学支援金 □学び直し支援金）の受給資格を有する（補助要件を満たす）者です。
・納付金等について、（□未済なし / □未済あり（　　円）

学校の名称
学校長の氏名
印
学校の電話番号

## 【6】 ឯកសារដែលត្រូវដាក់ជាមួយទម្រង់ពាក្យស្នើសុំ

○<u>ឯកសារដែលបង្ហាញថាលោកអ្នកទទួលជំនួយមុខរបរឬដែលបង្ហាញស្ថានភាពពន្ធ</u>

- សូមគូស (☑) ស្ថានភាពប្រាក់ចំណូលរបស់លោកអ្នក។
- សូមអានកំណត់សម្គាល់រួចគូស (☑) ឯកសារដែលលោកអ្នកនឹងដាក់។

○<u>ឯកសារដែលបង្ហាញសញ្ជាតិ / ស្ថានភាពស្នាក់នៅ</u>

- សូមគូស (☑) សញ្ជាតិ / ស្ថានភាពស្នាក់នៅដែលត្រូវ។

【ការប្រើឯកសារដូចគ្នានឹងប្រាក់ជំនួយថ្លៃសិក្សា】

- សូមគូស ☑ ប្រសិនបើលោកអ្នកយល់ព្រមឲ្យប្រើឯកសារដែលបានដាក់សម្រាប់ប្រាក់ជំនួយថ្លៃសិក្សាវិទ្យាល័យ។

## 【7】 ការសន្យានិងការប្រគល់សិទ្ធិ

- ប្រសិនបើលោកអ្នកយល់ព្រមសូមសរសេរឈ្មោះអ្នកដាក់ពាក្យ (ឈ្មោះឪពុកម្តាយឬអាណាព្យាបាល)ដើម្បីធ្វើការសន្យានិងការប្រគល់សិទ្ធិ។

# 6 – 2　លិខិតបញ្ជាក់ការទទួលជំនួយសង្គម (តែអ្នកដែលពាក់ព័ន្ធ)

○លិខិតបញ្ជាក់មួយក្នុងចំណោមខាងក្រោមដែលបង្ហាញថា នៅ**ថ្ងៃទី 1 ខែកក្កដាឆ្នាំ 2026** លោកអ្នកកំពុងទទួល **<u>ជំនួយមុខរបរ (ថ្លៃចូលរៀនវិទ្យាល័យ)</u>**

① **លិខិតបញ្ជាក់ការទទួលបានជំនួយសម្រាប់ការសិក្សានៅវិទ្យាល័យ** (ថ្លៃចូលរៀនវិទ្យាល័យ) (ទម្រង់លេខ 2)

※ សូមយកទម្រង់ពីសាលា ឬគេហទំព័ររបស់ខេត្ត ហើយស្នើសុំការបញ្ជាក់ពីការិយាល័យសុខុមាលភាពសង្គម (福祉事務所)។

② **លិខិតបញ្ជាក់ការទទួលបានជំនួយសង្គម**ដែលចេញដោយការិយាល័យសុខុមាលភាពសង្គម និងបញ្ជាក់ពីការទទួលបានជំនួយសម្រាប់ការសិក្សានៅវិទ្យាល័យ (ថ្លៃចូលរៀនវិទ្យាល័យ)

# 6 – 3　លិខិតបញ្ជាក់ពន្ធជាដើម (តែអ្នកដែលពាក់ព័ន្ធ)

○សូមដាក់ឯកសារណាមួយខាងក្រោម ដែលអាចបញ្ជាក់ចំនួនសរុបនៃពន្ធលើប្រាក់ចំណូលក្នុងពន្ធខេត្ត និងពន្ធក្រុង ស្រុក ឬឃុំ សម្រាប់ឆ្នាំសារពើពន្ធ2026 ។

(ត្រូវការ **<u>សម្រាប់ឪពុកម្តាយ/អាណាព្យាបាលគ្រប់រូប</u>**)

**① លិខិតបញ្ជាក់ការបង់ពន្ធ (មិនបង់ពន្ធ) ឆ្នាំហិរញ្ញវត្ថុ 2026 (ពន្ធលំនៅដ្ឋានក្រុងនិងខេត្ត)**

※សូមស្នើសុំចេញលិខិតនេះនៅការិយាល័យរដ្ឋបាលក្រុង ស្រុក ឬឃុំដែលពាក់ព័ន្ធ។

**② លិខិតជូនដំណឹងពន្ធលំនៅដ្ឋានពីនិយោជកឆ្នាំ 2026**

※សម្រាប់បុគ្គលិកក្រុមហ៊ុន ឬមន្ត្រីរាជការ ជាទូទៅត្រូវបានផ្តល់ដោយកន្លែងធ្វើការនៅប្រហែលខែមិថុនា។

**③ លិខិតជូនដំណឹងបង់ពន្ធលំនៅដ្ឋានឆ្នាំ 2026 ពីក្រុង ទីប្រជុំជន ឬភូមិ**

※សម្រាប់អ្នកប្រកបអាជីវកម្មផ្ទាល់ខ្លួនជាដើម ជាទូទៅត្រូវបានផ្ញើដោយអាជ្ញាធរមូលដ្ឋាននៅប្រហែលខែមិថុនា។

# 6 – 4　ឯកសារបញ្ជាក់សញ្ជាតិ និងព័ត៌មានពាក់ព័ន្ធ (អ្នកដាក់ពាក្យទាំងអស់ត្រូវដាក់ជូន)

សូមដាក់ឯកសារដែលបង្ហាញសញ្ជាតិនិងស្ថានភាពស្នាក់នៅរបស់ **សិស្ស**។ ※មិនមែនរបស់ឪពុកម្តាយទេ។

| សញ្ជាតិ / ស្ថានភាពស្នាក់នៅ | ឯកសារត្រូវដាក់ | កំណត់សម្គាល់ |
|---|---|---|
| សញ្ជាតិជប៉ុន | ច្បាប់ចម្លងលិខិតបញ្ជាក់ទីលំនៅ (ច្បាប់ដើម មិនទទួលច្បាប់ថតចម្លង) | ・សូមដាក់លិខិតបញ្ជាក់ទីលំនៅដែលចេញ ចាប់ពីថ្ងៃទី 1 ខែមករាឆ្នាំ 2026 |
| អ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស | ・ច្បាប់ចម្លងលិខិតបញ្ជាក់អ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេសឬ<br>・ច្បាប់ចម្លងលិខិតបញ្ជាក់ទីលំនៅ (ច្បាប់ដើម)<br>※ត្រូវបង្ហាញសញ្ជាតិស្ថានភាពរយៈពេលស្នាក់នៅជាដើម | ・សូមដាក់លិខិតបញ្ជាក់ទីលំនៅដែលចេញ ចាប់ពីថ្ងៃទី 1 ខែមករាឆ្នាំ 2026 |
| អ្នកស្នាក់នៅអចិន្ត្រៃយ៍<br>ប្តីប្រពន្ធឬកូនរបស់ជនជាតិជប៉ុន<br>ប្តីប្រពន្ធឬកូនរបស់អ្នកស្នាក់នៅអចិន្ត្រៃយ៍<br>អ្នកស្នាក់នៅរយៈពេលវែង<br>និស្សិតបរទេស (លើកលែងសិស្សថ្មី) | ・ច្បាប់ចម្លងប័ណ្ណស្នាក់នៅឬ<br>・ច្បាប់ចម្លងលិខិតបញ្ជាក់ទីលំនៅ (ច្បាប់ដើម)<br>※ត្រូវបង្ហាញសញ្ជាតិស្ថានភាពរយៈពេលស្នាក់នៅជាដើម | ・សូមដាក់លិខិតបញ្ជាក់ទីលំនៅដែលចេញ ចាប់ពីថ្ងៃទី 1 ខែមករាឆ្នាំ 2026<br>・អ្នកស្នាក់នៅរយៈពេលវែង៖តែអ្នកដែលត្រូវបានទទួលស្គាល់ ថាមានបំណងរស់នៅជប៉ុនជាអចិន្ត្រៃយ៍ |
| ស្នាក់នៅជាមួយគ្រួសារ | ・ច្បាប់ចម្លងប័ណ្ណស្នាក់នៅឬ<br>・ច្បាប់ចម្លងលិខិតបញ្ជាក់ទីលំនៅ (ច្បាប់ដើម)<br>※ត្រូវបង្ហាញសញ្ជាតិស្ថានភាពរយៈពេលស្នាក់នៅជាដើម<br>ខាងលើនិងមួយក្នុងចំណោមខាងក្រោមពីសាលាបឋមសិក្សា/អនុវិទ្យាល័យជប៉ុន៖<br>・ច្បាប់ចម្លងសញ្ញាបត្រឬ<br>・លិខិតបញ្ជាក់ការបញ្ចប់ការសិក្សា | ・សូមដាក់លិខិតបញ្ជាក់ទីលំនៅដែលចេញ ចាប់ពីថ្ងៃទី 1 ខែមករាឆ្នាំ 2026<br>・«បឋមសិក្សា/អនុវិទ្យាល័យ» រួមបញ្ចូលសាលាអប់រំពិសេស (បឋម/អនុ) សាលាអប់រំកាតព្វកិច្ច និងវគ្គដំបូងនៃសាលាមធ្យមសិក្សា<br>・តែអ្នកដែលមានបំណងធ្វើការនិងស្នាក់នៅ នៅជប៉ុនក្រោយវិទ្យាល័យ |

# 6 – 5　ច្បាប់ចម្លងសៀវភៅធនាគារជាដើម (អ្នកដាក់ពាក្យទាំងអស់ត្រូវដាក់ជូន)


○ សូមដាក់ច្បាប់ចម្លងសៀវភៅគណនីធនាគារ ឬឯកសារផ្សេងទៀតដែលអាច**<u>បញ្ជាក់ឈ្មោះម្ចាស់គណនីបាន។</u>**

○ សូមកំណត់យកគណនីធនាគាររបស់សិស្សផ្ទាល់ ឬអាណាព្យាបាល។

※ ប្រសិនបើប្រើគណនីធនាគាររបស់បុគ្គលផ្សេងក្រៅពីសិស្ស ឬអាណាព្យាបាល ត្រូវដាក់លិខិតប្រគល់សិទ្ធិ។

※ សូមជ្រើសរើសគណនីធនាគារដែលអាចទទួលប្រាក់ផ្ទេរចូលបានដោយប្រាកដ។

# 6 – 6　លិខិតប្រគល់សិទ្ធិ (តែសិស្សនៅវិទ្យាល័យជាតិឬសាធារណៈ ក្រៅពី សាលាខេត្តកាណាហ្គាវ៉ា)



(保護者等→学校長)

年　月　日

学校長　殿

委　任　状

私が支給を受ける高校生等奨学給付金を授業料以外に学校へ納付する下記納付金・積立金の未済に充てることについて了承し、その事務手続きを学校長に委任します。

| | |
|---|---|
| 申請者住所 | 〒 |
| ふりがな | |
| 申請者氏名 | |
| ふりがな | |
| 申請対象の高校生等氏名 | |
| 納付金・積立金の未済額（授業料以外） | 円 |

※　授業料以外に学校へ納付する納付金・積立金に未済がある場合に、保護者の方から学校長へ提出する委任状です。未済がなければ、提出の必要はありません。

○ ត្រូវដាក់លិខិតប្រគល់សិទ្ធិជូនសាលារៀន ក្នុងករណីដូចខាងក្រោម៖

- សិស្សកំពុងសិក្សានៅ**វិទ្យាល័យជាតិ ឬវិទ្យាល័យសាធារណៈ ក្រៅពីសាលា ដែលគ្រប់គ្រងដោយខេត្តកាណាហ្គាវ៉ា**។
- ក្នុងករណីដែលមានប្រាក់ចំណាយលើការអប់រំក្រៅពីថ្លៃសិក្សា ដែលនៅ**មិនទាន់បានបង់ ត្រូវដាក់លិខិតប្រគល់សិទ្ធិជូនសាលារៀន**។

○ សិស្សដែលកំពុងសិក្សានៅសាលាក្នុងខេត្តកាណាហ្គាវ៉ាមិនចាំបាច់ដាក់នោះទេ។

○ សូមបំពេញអាសយដ្ឋាន និងឈ្មោះរបស់អ្នកដាក់ពាក្យ (អាណាព្យាបាលជាដើម) ឈ្មោះសិស្សដែលស្នើសុំប្រាក់ឧបត្ថម្ភ និងចំនួនប្រាក់ចំណាយលើការអប់រំក្រៅពីថ្លៃសិក្សា ដែលនៅមិនទាន់បានបង់។

# 7 ផ្សេងៗ

- **អំពីការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ក្នុងករណីដែលឯកសណ្ឋានសាលាត្រូវបានបាត់បង់ ឬខូចខាតដោយសារគ្រោះមហន្តរាយ ហើយចាំបាច់ត្រូវទិញថ្មី**

សម្រាប់គ្រួសារដែលកំពុងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការសិក្សា ប្រសិនបើឯកសណ្ឋានដែលសាលាតម្រូវឱ្យសិស្សស្លៀកពាក់ ត្រូវបានបាត់បង់ ឬខូចខាតដោយសារគ្រោះមហន្តរាយជាដើម ហើយចាំបាច់ត្រូវទិញថ្មី អាចទទួលបានប្រាក់ឧបត្ថម្ភបន្ថែម។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងសាលាដែលសិស្សកំពុងសិក្សា ឬផ្នែកហិរញ្ញវត្ថុនៃគណៈកម្មាធិការអប់រំខេត្តកាណាហ្គាវ៉ា។

# 8　ទំនាក់ទំនង

- ព័ត៌មានលម្អិតនិងទម្រង់ពាក្យស្នើសុំមាននៅលើគេហទំព័រខេត្តឬនៅការិយាល័យសាលា។
- **គេហទំព័រខេត្ត៖ https://www.pref.kanagawa.jp/docs/en7/cnt/f531013/**
- **ទំនាក់ទំនង៖**ការិយាល័យរដ្ឋបាលនៃវិទ្យាល័យដែលសិស្សកំពុងសិក្សា ឬ
  ក្រុមការងារអាហារូបករណ៍វិទ្យាល័យ នៃផ្នែកហិរញ្ញវត្ថុ
  គណៈកម្មាធិការអប់រំខេត្តកាណាហ្គាវ៉ា
  **ទូរស័ព្ទ៖ ０４５－２１０－８２５１ (លេខទំនាក់ទំនងផ្ទាល់)**